REDD+ CAMBODIA

# ព្រឹត្តិបត្រប្រចាំត្រីមាស

លេខទី៣
ខែមករា ឆ្នាំ២០១៤




## កម្មវិធីប្រគំតន្ត្រីនៃកម្មវិធីរេដ+ ស្តីពី "ព្រៃឈើរបស់យើង ភពផែនដីបៃតង"

កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៣ លេខាធិការដ្ឋានរេដ+កម្ពុជា បានរៀបចំកម្មវិធីប្រគំតន្ត្រីមួយ នៅមជ្ឈមណ្ឌលកំសាន្តកោះពេជ្រ រាជធានីភ្នំពេញ ដើម្បីលើកកម្ពស់ចំណេះដឹងសាធារណៈអំពីកម្មវិធីរេដ+ ( REDD+ ) នៅកម្ពុជា។ កម្មវិធីប្រគំតន្ត្រីនេះមានការចូលរួមសហការរៀបចំពីក្រុមហ៊ុន Smart ដែលជាក្រុមហ៊ុន ផ្តល់សេវាកម្មទូរស័ព្ទចល័តឈានមុខមួយនៅកម្ពុជា និងក្រុមហ៊ុនកូកាកូឡា។

ការប្រគំតន្ត្រីនេះទទួលបានភ្ញៀវមកចូលរួមទស្សនាប្រមាណ ៦.០០០នាក់ គឺច្រើនជាងការរំពឹងទុកដែលមានចំនួនត្រឹមតែ ២.០០០នាក់ប៉ុណ្ណោះ។ កម្មវិធីប្រគំតន្ត្រីនេះមានការសំដែង ដែលរំលេចចេញនូវសារប្រយោជន៍នៃការការពារព្រៃឈើ។ កម្មវិធីប្រគំតន្ត្រី បានចាប់ផ្តើមជាមួយនឹងការសំដែងរបាំរបស់បងប្អូនជនជាតិភាគតិចទំពួន មកពីខេត្តរតនគិរី ហើយបន្តដោយការសំដែងរបស់តារាល្បីៗជាច្រើនរូបទៀត។ តារាចំរៀងឆ្នើម ឱក សុគន្ធកញ្ញា បានអង្រួនទឹកចិត្តទស្សនិកជនយ៉ាងផុលផុសនៅខណៈដែល ឱជេ ឃ្លាំង បាននិពន្ធចងក្រងពាក្យពេចន៍ បរិយាយអំពីការការពារព្រៃឈើគួរឲ្យសរសើរ។ ក្រុមតារាកំប្លែងពែកមី នៃក្រុមទូរទស្សន៍ CTN ដែលជាក្រុមចុងក្រោយនៃកម្មវិធីនេះក៏បានធ្វើឲ្យទស្សនិកជនសប្បាយរីករាយយ៉ាងខ្លាំងផងដែរ។

ក្នុងវេលានៃការប្រគំតន្ត្រីនេះ ជ័យលាភីពីការប្រកួតគំនូរកុមារស្តីពី "មនុស្ស និងព្រៃឈើ" ត្រូវបានប្រគល់ជូនដល់កុមារពីរក្រុមដែលជាអ្នកឈ្នះការប្រកួតមានអាយុចាប់ពី ៧ដល់១១ឆ្នាំ និងពីអាយុ ១២ដល់១៤ឆ្នាំ។ ផ្ទាំងគំនូរទាំងនោះមានលក្ខណៈឆ្នៃប្រឌិត និងមានគុណភាពខ្ពស់។

រោងដាក់តាំងសម្ភារៈរបស់លេខាធិការដ្ឋានរេដ+កម្ពុជា ក៏បានទាក់ទាញទស្សនិកជនយ៉ាងក្រាស់ក្រែលផងដែរដោយពួកគេចូលចិត្តលេងល្បែងប្រាជ្ញាមួយអំពីសត្វព្រៃ ដែលរស់នៅក្នុងព្រៃនៃប្រទេសកម្ពុជា។ ជាមួយនេះដែរ ការដាក់តាំងពិព័រណ៍គំនូរអំពីមនុស្ស និងព្រៃព្រឹក្សាដែលគូរដោយកុមារ បានធ្វើឲ្យទស្សនិកជនមានការកោតសរសើរជាខ្លាំងពីរូបគំនូរទាំងនោះ ហើយពួកគាត់ក៏អាចទទួលបាននូវព័ត៌មានអំពីរេដ+ និងការការពារព្រៃឈើនៅកម្ពុជាផងដែរ។

កម្មវិធីប្រគំតន្ត្រីនេះ បានសម្រេចជោគជ័យយ៉ាងត្រចះត្រចង់ ហើយយើងគ្រោងនឹងរៀបចំកម្មវិធីប្រគំតន្ត្រីនៅតាមខេត្តមួយចំនួនដែលសម្បូរព្រៃឈើបន្តទៀត។

សម្រាប់ព័ត៌មានបន្ថែម និងរូបថតនានាអំពីកម្មវិធីប្រគំតន្ត្រី អាចរកបាននៅទំព័រព័ត៌មានសង្គម ( Facebook ) របស់រេដ+កម្ពុជា និងគេហទំព័រខាងក្រោម៖

*https://www.facebook.com/pages/Cambodia-REDD-National-Programme/281996938602896*

*http://www.cambodia-redd.org/*

## មាតិកា

◊ អំពីគម្រោង **CAM-REDD** ............ ២
◊ សេចក្តីសម្រេចពីសន្និសីទកំពូលលើកទី១៩ ............ ៣
◊ ទស្សនកិច្ចសិក្សានៅកម្ពុជាពីប្រទេសអនុវត្តន៍រេដ+ ....... ៤

# តើនរណាខ្លះអនុវត្តន៍រេដ+កម្ពុជា?





ទស្សនកិច្ចទៅតំបន់គម្រោងសាកល្បងនៅសីមា ខេត្តមណ្ឌលគិរី
រូបភាព៖ RTS

## គម្រោង CAM-REDD

CAM-REDD ( Cambodia Reducing Emissions from Deforestation and Forest Degradation ) គឺគម្រោងមួយនៃក្របខ័ណ្ឌការងារគាំទ្រការអនុវត្តផែនទីបង្ហាញផ្លូវរេដ+កម្ពុជា ដែលទទួលបានការគាំទ្រពីរដ្ឋបាលព្រៃឈើនៃរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលជប៉ុនតាមរយៈភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ( JICA ) កាលពីថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០១១។

CAM-REDD បានជួយផ្តួចផ្តើមគំនិតអំពីភាពជាស្រេចនៃរេដ+ ដែលមានលទ្ធផលបួនសំខាន់ក្នុងផែនទីបង្ហាញផ្លូវរេដ+ ៖

លទ្ធផលទី១ ៖ ជួយដល់ការងារគ្រប់គ្រងថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការត្រៀមជាស្រេចនៃការអនុវត្តរេដ+និងភាគីចូលរួមពាក់ព័ន្ធនានាដោយផ្អែកលើគោលការណ៍ផែនទីបង្ហាញផ្លូវ។

លទ្ធផលទី២ ៖ ជួយរៀបចំយុទ្ធសាស្ត្ររេដ+ថ្នាក់ជាតិ និងបែបបទក្នុងការអនុវត្ត។

លទ្ធផលទី៣ ៖ ជួយកែលម្អសមត្ថភាពគ្រប់គ្រងការងាររេដ+ក្នុងក្របខ័ណ្ឌគម្រោង និងនៅថ្នាក់ក្រោមជាតិ។

លទ្ធផលទី៤ ៖ ជួយរៀបចំប្រព័ន្ធត្រួតពិនិត្យ និងក្របខ័ណ្ឌកម្រិតយោង/កម្រិតបញ្ចេញឧស្ម័នយោង ( RLs/REL ) ព្រមទាំងសមត្ថភាពអនុវត្តន៍។

## ព័ត៌មានទំនាក់ទំនងសមាជិករេដ+នៅកម្ពុជា

ប្រធានក្រុមការងាររេដ+៖ **ឯ.ឧ ជា សំអាង**
- ◊ អ៊ីម៉ែល៖ samangfa@gmail.com

អនុប្រធានក្រុមការងាររេដ+៖ **លោក គឹម ណុង**
- ◊ អ៊ីម៉ែល៖ kimnongmoe@yahoo.com

ប្រធានលេខាធិការដ្ឋានក្រុមការងាររេដ+៖ **លោក ឃុន វឌ្ឍនា**
- ◊ អ៊ីម៉ែល៖ vathana.khun@gmail.com

អនុប្រធានលេខាធិការដ្ឋានក្រុមការងាររេដ+៖ **លោក អ៊ុយ កាម៉ាល់**
- ◊ អ៊ីម៉ែល៖ kamaluy@yahoo.com

អ្នកសម្របសម្រួលកម្មវិធីរេដ+កម្ពុជា៖ **លោក លន់ គឹមហ៊ី**
- ◊ អ៊ីម៉ែល៖ kimhy.lun@undp.org

មន្ត្រីផ្នែកទំនាក់ទំនងកម្មវិធីរេដ+កម្ពុជា៖ **កញ្ញា ធី ហៀង**
- ◊ អ៊ីម៉ែល៖ heang.thy@undp.org

ប្រធានក្រុមប្រឹក្សាយោបល់៖ **លោកបណ្ឌិត សៀក សុផាត**
- ◊ អ៊ីម៉ែល៖ seak.sophat@rupp.edu.kh

អនុប្រធានក្រុមប្រឹក្សាយោបល់៖ **លោក សារ ថ្លៃ**
- ◊ អ៊ីម៉ែល៖ sathlay@yahoo.com

CAM-REDD ត្រូវបានស្នើសុំឲ្យជួយដល់ការងារពាក់ព័ន្ធជាមួយលទ្ធផលទី៣ និងទី៤ ហើយបានជួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់គម្រោងសាកល្បងរេដ+នៅខេត្តឧត្តរមានជ័យ និងតំបន់ព្រៃការពារសីម៉ា។ លើសពីនេះទៅទៀត CAM-REDD ក៏បានជួយដល់តំបន់ព្រៃការពារដទៃទៀត ដូចជា តំបន់ព្រៃការពារជួរភ្នំក្រវាញផ្នែកកណ្តាល តំបន់ព្រៃការពារនៅខេត្តព្រះវិហារ និងបណ្តាតំបន់ព្រៃមានសក្តានុពលសម្រាប់ការពារនៅផ្នែកខាងលិចសៀមប៉ាង វ៉ុនសៃ-សៀមប៉ាង និងតំបន់ព្រៃឡង់។

CAM-REDD នឹងបន្តជួយគាំទ្រដល់ការងារអនុវត្តន៍ផែនទីបង្ហាញផ្លូវរេដ+កម្ពុជា រហូតដល់ខែឧសភា ឆ្នាំ២០១៦៕

*សម្រាប់ព័ត៌មានបន្ថែម៖ http://www.cambodia-redd.org/category/supporting-redd-framework/cam-redd#sthash.3ulcXfpC.dpuf*

## ព្រឹត្តិការណ៍នាពេលខាងមុខ

### សិក្ខាសាលា ស្តីពី ការចាប់ផ្តើមគម្រោងមូលនិធិភាពជាដៃគូកម្មវិធីកាបូនព្រៃឈើ( FCPF ) ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១៤

កម្ពុជាបានទទួលទឹកប្រាក់ចំនួន ៣,៨លានដុល្លារ ពីមូលនិធិភាពជាដៃគូកម្មវិធីកាបូនព្រៃឈើ ដើម្បីគាំទ្រការអនុវត្តផែនទីបង្ហាញផ្លូវរេដ+។ មូលនិធិនេះ នឹងប្រតិបត្តិដោយកម្មវិធីអភិវឌ្ឍសហប្រជាជាតិ ( UNDP )។ សិក្ខាសាលា នឹងរៀបចំឡើងនៅដើមឆ្នាំ២០១៤ ក្នុងគោលបំណងផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធ ធ្វើការត្រួតពិនិត្យលើលទ្ធផលរំពឹងទុក ក្របខ័ណ្ឌការងារ ព្រមទាំងសកម្មភាពដែលបានគ្រោងទុកនានា។ ព័ត៌មានបន្ថែមនឹងមានចែកជូនតាមរយៈក្រុមប្រឹក្សាយោបល់ និងមាននៅលើគេហទំព័ររបស់កម្មវិធីរេដ+កម្ពុជា។

### កិច្ចប្រជុំលើកទី៣របស់ក្រុមការងាររេដ+ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤

ក្រុមការងាររេដ+កម្ពុជា នឹងជួបប្រជុំនៅថ្ងៃទី២១ ខែកុម្ភៈខាងមុខ។ របៀបវារៈសំខាន់ៗ នឹងជជែកអំពីវិសាលភាពនៃយន្តការរេដ+ កម្រិតណាដែលគួរអនុវត្តន៍រេដ+នៅក្នុងប្រទេសកម្ពុជា (ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ)។ ក្រុមពិគ្រោះយោបល់ បានជួបប្រជុំនៅមុនថ្ងៃនេះ ដើម្បីរៀបចំពង្រាងទស្សនៈ ឬមតិយោបល់ពីអ្នកពាក់ព័ន្ធនានា។

# ស្វែងយល់អំពីរេដ+

## សេចក្តីសម្រេចពីសន្និសីទបណ្តាប្រទេសជាភាគីលើកទី១៩ របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពី ការប្រែប្រួលអាកាសធាតុ ( UNFCCC ) ៖ ឥឡូវ UNFCCC  បានសម្រេចរួចរាល់សម្រាប់រេដ+

អស់រយៈពេល៩ឆ្នាំបន្ទាប់ពីរេដ+ ត្រូវបានណែនាំជាលើកដំបូងទៅ UNFCCC នៅក្នុងសន្និសីទបណ្តាប្រទេសជាភាគីលើកទី១១ នៅទីក្រុងម៉ុងរ៉េអាល ប្រទេសកាណាដា កាលពីឆ្នាំ២០០៥ ហើយទីបំផុតបណ្តាភាគីទាំងអស់ អាចយល់ព្រមលើរាល់សេចក្តីសម្រេចដ៏ហ្មត់ចត់ស្តីពីរេដ+នៅក្នុងសន្និសីទបណ្តាប្រទេសជាភាគីលើកទី១៩ នាពេលថ្មីៗនេះ នៅទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ។

សេចក្តីសម្រេចចិត្តទាំងនោះ គ្របដណ្តប់លើទិដ្ឋភាពនានា ដូចជាប្រព័ន្ធធានាសុវត្ថិភាព ការត្រួតពិនិត្យព្រៃឈើ កត្តាដែលបណ្តាលឲ្យបាត់បង់ព្រៃឈើ ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ( MRV ) និងកម្រិតយោង ( RLs ) ព្រមទាំងការងារសម្របសម្រួលគាំទ្រ និងសកម្មភាពផ្អែកលើ លទ្ធផល ហើយដែលឥឡូវនេះត្រូវបានគេឲ្យឈ្មោះថា ក្របខ័ណ្ឌការងារទីក្រុងវ៉ាសូវី ស្តីពី រេដ+។ រួមជាមួយនឹងសេចក្តីសម្រេចចិត្តទាំងនេះ និងសេចក្តីសម្រេចចិត្តមុនៗរបស់ UNFCCC បច្ចុប្បន្នបណ្តាប្រទេសនានា អាចបន្តទៅមុខជាមួយរេដ+ បានយោងទៅតាមលក្ខខណ្ឌរបស់ UNFCCC និងការបង់ថ្លៃផ្អែកលើលទ្ធផល ( result-based actions )។

នៅមុនសន្និសីទកំពូលលើកទី១៩ ប្រទេសមួយចំនួន គឺស្ថិតនៅក្នុងដំណើរការត្រៀមខ្លួនជាស្រេចសម្រាប់រេដ+ ប៉ុន្តែនៅពេលចាប់ផ្តើមទទួលមូលនិធិផ្អែកតាមលទ្ធផល ( result-based funding ) ជម្រើសមួយចំនួនដែលមាន គឺគម្រោងផ្អែកលើទីផ្សារកាបូនស្ម័គ្រចិត្ត បូករួមនឹងគម្រោងផ្អែកលើកិច្ចព្រមព្រៀងទ្វេភាគីមួយចំនួនប៉ុណ្ណោះ។

ដូច្នេះ លទ្ធផលពីសន្និសីទបណ្តាប្រទេសជាភាគីលើកទី១៩ គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅមុខ ពីព្រោះរាល់ធាតុចាំបាច់ទាំងអស់សម្រាប់រេដ+ ឥឡូវត្រូវបានរៀបរយហើយ ( សូមមើលដ្យាក្រាមខាងក្រោម )។ បច្ចុប្បន្ន ប្រទេសនានា អាចអនុវត្តន៍រេដ+នៅថ្នាក់ជាតិ ឬនៅថ្នាក់ក្រោមជាតិ ក្នុងនាមជាវិធីសាស្ត្របណ្តោះអាសន្នមួយ ហើយស្វែងរកការផ្ទៀងផ្ទាត់ និងការគាំទ្រ ព្រមទាំងរាល់ការបង់ថ្លៃផ្អែកលើលទ្ធផលនៅក្នុងប្រព័ន្ធរបស់ UNFCCC។

ប្រទេសនានាអាចទទួលបានការត្រួតពិនិត្យលើកម្រិតយោងដែលបានស្នើឡើងរបស់ពួកគេ ហើយអាចដាក់ព័ត៌មាននានា ជាឧទាហរណ៍ព័ត៌មានស្តីពីលទ្ធផល ប្រព័ន្ធធានាសុវត្ថិភាព យុទ្ធសាស្ត្ររេដ+ជាតិជាដើម ទៅក្នុងមជ្ឈមណ្ឌលព័ត៌មានដែលបានបង្កើតឡើងនៅក្រោមគេហទំព័ររបស់ UNFCCC ( http://unfccc.int/2860.php )។

## ធាតុនានាសម្រាប់រេដ+ និងសេចក្តីសម្រេចចិត្តរបស់សន្និសីទបណ្តាប្រទេសជាភាគី



# ទស្សនកិច្ចសិក្សានៅកម្ពុជាពីប្រទេសអនុវត្តន៍រេដ+



ការជួបប្រជុំគ្នាជាមួយសហគមន៍ក្រាំងសេរី និងប្រតិភូ ចុះទស្សនកិច្ចនៅក្នុងសហគមន៍ព្រៃឈើក្រាំងសេរី ខេត្តកំពង់ស្ពឺ
រូបភាព៖ RTS

ពីថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣ ប្រតិភូបីក្រុមមកពីប្រទេស ភូមា ស្រីលង្កា និងវៀតណាម បានធ្វើទស្សនកិច្ចមកកម្ពុជាដើម្បីសិក្សារៀនសូត្រ ដកបទពិសោធន៍ អំពីភាគីចូលរួមពាក់ព័ន្ធ និងការទំនាក់ទំនងនៅកម្ពុជា និងដើម្បីផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក។ ប្រតិភូមួយចំនួនទៀត គឺបានអញ្ជើញមកពីប្រទេសនេប៉ាល់ ប៉ាគីស្ថាន និងប៉ាពួញ៉ូហ្គីនី។

បន្ថែមពីលើការធ្វើបទបង្ហាញ ពីអ្នកពាក់ព័ន្ធក្នុងកម្មវិធីរេដ+កម្ពុជា ប្រតិភូទាំងនោះ ក៏បានទៅទស្សនកិច្ចនៅសហគមន៍ព្រៃឈើក្រាំងសេរី សហគមន៍តំបន់ការពារ និងទេសចរណ៍ចំបក់នៅខេត្តកំពង់ស្ពឺ។

ទស្សនកិច្ចនៅតាមទីកន្លែងទាំងនេះ បានបង្កើតនូវបរិយាកាសល្អមួយ ដើម្បីរៀនសូត្រពីការអនុវត្តការងារគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍។ វាក៏បានជួយឲ្យសមាជិកប្រតិភូទាំងអស់ អាចឆ្លុះបញ្ចាំងនូវអ្វីដែលបានពិភាក្សានៅក្នុងថ្ងៃទី១។ សមាជិកប្រតិភូទាំងអស់ យល់ឃើញថាដំណើរការរៀបចំបង្កើតក្រុមការងារពិគ្រោះយោបល់ មានលក្ខណៈគួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំង ព្រោះវាជាចំនុចចាប់ផ្តើមបង្កើតសម្ភារៈផ្សព្វផ្សាយជាទូទៅមួយ។ សមាជិកប្រតិភូទាំងអស់បានឲ្យដឹងថា ពួកគាត់មានបំណងធ្វើតាមដំណើរការអនុវត្តនេះនៅក្នុងប្រទេសរបស់ពួកគាត់ដែលរួមបញ្ចូលទាំងការបកប្រែសន្ទានុក្រមរេដ+ ដែលបានរៀបចំឡើងដោយរេដ+កម្ពុជាទៅជាភាសាជាតិរបស់ពួកគាត់។ ជាមួយគ្នានេះ ក៏មានការពិភាក្សាយ៉ាងផុលផុសនៅក្នុងវគ្គពិភាក្សាទូទៅ អំពីថាតើគួរធានាការទំនាក់ទំនងនៅតែបន្តក្នុងចំណោមប្រទេសទាំងនេះយ៉ាងដូចម្តេច ដើម្បីធានាឲ្យមានការផ្លាស់ប្តូរព័ត៌មានបន្តទៀតនាពេលអនាគត។

នាក្នុងឱកាសទស្សនកិច្ចសិក្សានេះ ឯកឧត្តមបណ្ឌិត ឆេង គឹមស៊ុន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ បានមានប្រសាសន៍ថា "នេះមិនមែនជាទីបញ្ចប់នៃការរៀនសូត្រពីគ្នាទៅវិញទៅមកនោះទេ ខ្ញុំសង្ឃឹមថា យើងអាចរៀនសូត្រពីគ្នាទៅវិញទៅមកជាធនធានមូលដ្ឋានអំពីរេដ+។ យើងត្រូវការបន្តចែករំលែកព័ត៌មាន ដោយហេតុថានេះជាផ្នែកមួយដែលយើងកំពុងសាកល្បងដោះស្រាយបញ្ហា ហើយកំហុសខ្លះអាចកើតមាន ប៉ុន្តែសង្ឃឹមថាជាជំហានៗ យើងនឹងធ្វើឲ្យមានការរីកចម្រើនឆ្ពោះទៅរកការអនុវត្តរេដ+"។

## បច្ចុប្បន្នភាពនៃគេហទំព័ររបស់ រេដ+កម្ពុជា

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅគេហទំព័ររេដ+កម្ពុជា៖ www.cambodia-redd.org។ ព័ត៌មានដែលបានដាក់បញ្ចូលថ្មីៗ៖

- *សម្ភារៈទំនាក់ទំនងផ្សព្វផ្សាយរបស់កម្មវិធីរេដ+*
- *កិច្ចប្រជុំលើកទី១ ស្តីពី ក្រុមបច្ចេកទេសរេដ+ទាំងបួន*
- *កិច្ចប្រជុំ ស្តីពី យន្តការមូលនិធិរេដ+ និងការបែងចែកចំណូល*
- *កិច្ចប្រជុំ ស្តីពី ការត្រៀមលក្ខណៈអនុវត្តន៍រេដ+កម្ពុជា និងមធ្យោបាយឆ្ពោះទៅមុខ*

ព័ត៌មានលម្អិតមានជូនពិស្តារនៅក្នុង៖
http://www.cambodia-redd.org/category/document-centre

## ព័ត៌មានទំនាក់ទំនងលេខាធិការដ្ឋាន

**លោក យុន វឌ្ឍនា**
ប្រធានលេខាធិការដ្ឋានក្រុមការងាររេដ+
#៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ភ្នំពេញ កម្ពុជា
លេខទូរស័ព្ទ៖ (+៨៥៥) ២៣ ២២៤ ២៥១
អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org
គេហទំព័រ៖ www.cambodia-redd.org